**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

ខុមហ្វ្រែល COMFRE P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org



**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហេរញ្ញិក
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឺន សែត**
**Mr. SEN Set**


ស.ប្រ.ក.៣/លេខ ០៣/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោត
# ក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងខេត្ត កំពត

*ភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភាឆ្នាំ ២០០៩*

ម្ចាស់ឆ្នោតប្រមាណ ៧០នាក់ ដែលតំណាងឱ្យសហគមន៍នេសាទ ព្រៃឈើ ដីធ្លី ... សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ ដែលមកពីស្រុកទាំង៧ និងក្រុងកំពត ក្នុងខេត្តកំពត បានជួបជុំគ្នានៅក្នុងសិក្ខាសាលាដើម្បីធ្វើការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពត នាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៩។ នៅក្នុងសិក្ខាសាលានេះដែលមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ៣១% បានបោះឆ្នោត កំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ក្នុងខេត្តកំពតដូចខាងក្រោម ដែលស្នើឱ្យអាជ្ញាធរខេត្ត រាជរដ្ឋាភិបាល និងអ្នកតំណាងរាស្ត្រយកចិត្តទុកដាក់ដោះស្រាយ និងបំពេញឱ្យបានក្នុងអាណត្តិនេះ :

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង ១០ នៅក្នុងខេត្ត កំពត** |
| --- |
| ១) ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្ររាល់មួយឆ្នាំម្តងក្នុងចំណោម ៧ ស្រុករួមមានស្រុកទឹកឈូ ស្រុកឈូក ស្រុកដងទង់ ស្រុកកំពង់ត្រាច ស្រុកបន្ទាយមាស ស្រុកជុំគីរី និងស្រុកអង្គរជ័យ ចាប់ពីឆ្នាំ ២០០៩ ដល់ ២០១២ យ៉ាងយូរ ត្រូវស្តារអោយបានគ្រប់ស្រុក ។ |
| ២) ផ្តល់ការបណ្តុះបណ្តាលទំនាក់ទំនងទីផ្សារ និងបង្កើតទីផ្សារ ដល់កសិករ ព្រមទាំងបង្កើនពន្ធការនាំចូលនូវផលិតផលកសិកម្ម ( អោយលើសពីពន្ធបច្ចុប្បន្ន) ពីខាងក្រៅដែលខេត្តកំពតមាន ( ស្រូវ បន្លែ ដូង ពោត..) ចាប់ពីឆ្នាំ ២០០៩ ដល់ ២០១២ |
| ៣) ចាប់ពីឆ្នាំ ២០០៩ ទៅ អាជ្ញាធរជលផលត្រូវតែទទួលស្គាល់ និងចុះបញ្ជី សហគមន៍នេសាទរបស់ប្រជាពលរដ្ឋដែលបានបង្កើតឡើងហើយបានដាក់ពាក្យទៅ និងបង្ក្រាបបទល្មើសនេសាទទាំងអស់អោយបាន [100%] ។ |

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់ ។

| |
|---|
| ៤) ផ្តល់មេធាវីដល់ប្រជាពលរដ្ឋក្រីក្រដោយឥតគិតថ្លៃ ហើយ [តុលាការ] ស៊ើបអង្កេតរឿងក្តី និងបណ្តឹងអោយបានច្បាស់លាស់ដល់ទីកន្លែង គ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ នៅខេត្តកំពតចាប់ពីឆ្នាំ ២០១០តទៅ |
| ៥) ចាត់វិធានការតាមផ្លូវច្បាប់ម៉ឹងម៉ាត់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ កងកំលាំងប្រដាប់អាវុធ និងអ្នកមានអំណាច មួយចំនួនដែលឃុបឃិត ជាមួយជនល្មើស កាប់បំផ្លាញព្រៃឈើដែលខុសច្បាប់ ក្នុងខេត្តកំពត ចាប់ពីឆ្នាំ ២០០៩ តទៅ ឱ្យបាន ១០០% |
| ៦) តម្លៃសេវាទូរស័ព្ទ ការប្រើប្រាស់ប្រព័ន្ធនីមួយៗសូមបញ្ចុះតម្លៃទូរស័ព្ទត្រឹមតែ ៣ សេន [ដុល្លារ] ក្នុងមួយនាទី [ឆ្លងប្រព័ន្ធ] យ៉ាងយូរត្រឹមឆ្នាំ ២០១០ និងនៅគ្រប់សាលាស្រុកទាំងអស់ ត្រូវមានប្រព័ន្ធអ៊ីនធឺណែតសំរាប់ប្រជាពលរដ្ឋប្រើប្រាស់ជាសាធារណៈដោយឥតគិតថ្លៃនៅស្រុកទាំង៧ និងក្រុងកំពត ខេត្តកំពត យ៉ាងយូរអោយបាននៅឆ្នាំ២០១១។ |
| ៧) បង្កើនប្រាក់បៀវត្សដល់គ្រូបង្រៀនឱ្យបានសមរម្យ គឺឱ្យបាន៤៥% ជារៀងរាល់ឆ្នាំដើម្បីលើកទឹកចិត្តគ្រូបង្រៀន។ |
| ៨) បង្កើតមជ្ឈមណ្ឌលសម្រាប់អប់រំកែប្រែអត្តចរិត និងបណ្តុះបណ្តាលវិជ្ជាជីវៈ (កាត់ដេរ ជួសជុលម៉ូតូ....) សម្រាប់ក្មេងអនាថា និងយុវជនគ្មានការងារធ្វើនៅក្រុងកំពតដោយកសាងអាគារចំនួន ២ខ្នង (សម្រាប់ប្រមូលក្មេង និងយុវជនអនាថា) ឱ្យរួចរាល់ក្នុងឆ្នាំ ២០១២។ |
| ៩) ស្តារឡើងវិញនូវទំនប់ទឹក ឃុំ កោះតូច ស្រុកទឹកឈូ ខេត្ត កំពត នៅចន្លោះឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១០ និងសូមបញ្ចុះតម្លៃប្រេង សាំងត្រឹមតែ ២០០០ រៀលក្នុងមួយលីត និងប្រេងម៉ាសូតក្នុងតម្លៃ ១០០០ រៀលក្នុងមួយលីត្រ។ |
| ១០) គ្រប់ស្ថាប័នឥណទានត្រូវយកការប្រាក់ទាបជាង ១%ក្នុងមួយខែ និងត្រូវមានការបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋពីការប្រើប្រាស់លុយកម្ចី មុននឹងអនុញ្ញាតខ្ចី ចាប់ពីឆ្នាំ ២០១០តទៅ។ |

អភិបាលរងខេត្តកំពត ឯកឧត្តម សាឡេះ សេន បានថ្លែងបើកសិក្ខាសាលាថា ឯកឧត្តមជឿថា អ្វីដែលម្ចាស់ឆ្នោតបានកំណត់នោះ [លក្ខខណ្ឌសន្ទស្សន៍] គឺនឹងមិនខុសពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលទេ ដែលកម្មវិធីនេះគ្របដណ្តប់គ្រប់ [សន្ទស្សន៍នៃវិស័យអាទិភាព]ទាំងអស់។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយ គណៈកម្មាធិការខុមហ្វ្រែល ដោយមានកិច្ចសហការជាមួយអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា (CWDCC) និងសមាគមធាងត្នោត (STT)។ សិក្ខាសាលានេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋ ដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី ៤

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ចំនួ ដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិន្ទុរៀ** អ្នកសម្របសម្រួលស្ថិតិផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៨៦